# គោលការណ៍សំរាប់បង្កើត បង្គោលឡាក់




**ទំហំបង្គោលឡាក់:**

បង្គោលឡាក់មានរាងជាសរសរ ដែលមាន៣ជ្រុង និងមានបណ្តោយ ១.៥ម៉ែត្រ និងទទឹងរាងជា ចតុកោណព្នាយ ដែលមានជ្រុងបាត ៤០សង់ទីម៉ែត្រ និងជ្រុងសងខាង មានប្រវែង ៣០សង់ទីម៉ែត្រ។

**ពណ៌បង្គោលឡាក់:**

បង្គោលឡាក់ត្រូវលាបជា ២ពណ៌ដាច់ពីគ្នា ដែលនៅផ្នែកខាងលើប្រវែង ៥០សង់ទីម៉ែត្រ ពនៃបៃតង នៅកណ្តាលប្រវែង ៥០សង់ទីម៉ែត្រ ពណ៌ក្រហម និង ផ្នែកខាងក្រោមមិនបាច់លាបពណ៌ទេ។

**ការសាងសង់បង្គោលឡាក់:**

បង្គោលត្រូវធ្វើពីស៊ីម៉ង់ត៍ដែលបង្កប់ដោយឆ្អឹងដែកនៅផ្នែកខាងក្នុង។

**ការដាក់បង្គោលឡាក់:**

បង្គោលត្រូវដាក់តាមចំណុចព្រំរបស់ព្រៃ  ប្រសិនបើព្រំព្រៃត្រង់ត្រូវដាក់ចំងាយពីគ្នា ២៥០ម៉ែត្រ ទៅ ៥០០ម៉ែត្រ បើជាព្រំកោងត្រូវដាក់ចំងាយពីគ្នា ៥០ម៉ែត្រ ទៅ ១០០ម៉ែត្រ បើនៅក្បែរ ភូមិ នោះត្រូវដាក់ចំងាយពីគ្នា ២៥០ម៉ែត្រ ទៅ ៥០០ម៉ែត្រ បើព្រំនៅជាប់ផ្លូវត្រូវបោះពីដើមផ្លូវរហូតដល់ចុងផ្លូវដោយមានចំងាយពីគ្នា ២៥០ម៉ែត្រ ទៅ ៥០០ម៉ែត្រ បើព្រំនៅតាមមាត់ទឹក ត្រូវបោះនៅត្រង់កន្លែងជួបនៃផ្លូវទឹក។

**ការសរសេរអក្សរ  និងដាក់ប្រសពលេខបង្គោលឡាក់:**

នៅផ្នែកខាងស្តាំនៃជ្រុងខាងតូចត្រូវសរសេរ លេខកូដបង្គោល និងកូអរដោនេនៃបង្គោល (មើលរូប)។ នៅផ្នែកខាងមុខនៃជ្រុងធំត្រូវសរសេរ ឈ្មោះ សហគមន៍ ព្រៃឈើ ឈ្មោះសង្កាត់ផ្នែករដ្ឋបាលព្រៃឈើ។ នៅផ្នែកខាងលើបង្គោល បង្ហាញ ពីទិសនិងចំងាយនៃបង្គោលនៅសងខាង។

**ឧបត្ថម្ភការបោះពុម្ពដោយ**

CFI USAID MacArthur